# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ការបង្ហាត់បង្រៀនអំពីប្រល័យពូជសាសន៍ ៖ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រ
## កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ការរស់នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ - ការសិក្សាអំពីប្រវត្តិខេត្តប៉ៃលិន

ឡូរ៉ា សាំម័រ

ជាកិច្ចចាប់ផ្តើម ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងអប់រំ និង មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់កិត្តិយសអញ្ជើញខ្ញុំចូលរួមនៅក្នុងកម្មវិធីបង្រៀនគ្រូបង្រៀនដ៏មានសារៈសំខាន់នេះ ។ ខ្ញុំមានកិត្តិយសខ្លាំងណាស់ ដែលបានរួមចំណែកនៅក្នុងកម្មវិធីមួយ មានការចូលរួមពីសំណាក់អ្នកប្រវត្តិសាស្ត្រជាតិ និង អន្តរជាតិ និង ដែលបានចូលរួមនៅក្នុងទំនើបភាវូបនីយកម្មនៃការបង្រៀនប្រវត្តិសាស្ត្រនេះ ។

តាមពិតទៅ នេះគឺជាការលំបាកមួយ! ភាគច្រើននៃការស្រាវជ្រាវរបស់ខ្ញុំគឺផ្តោតទៅរយៈកាលពីទសវត្សរ៍ឆ្នាំ១៩៤០មកដល់ឆ្នាំ១៩៧៩ ។ អត្ថបទខ្លះផ្តោតតែទៅលើរយៈកាលនៃសម័យសង្គមរាស្ត្រនិយម ឬ រយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។[១] សិក្សាស្រាវជ្រាវអំពីរបបនយោបាយជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៨៥មក បានធ្វើឲ្យខ្ញុំកាន់តែចាប់អារម្មអំពីទម្ងន់នៃអតីតកាលដែលមានទៅលើ "បច្ចុប្បន្នកាល" នីមួយៗ ហើយខ្ញុំកាន់តែចាប់អារម្មណ៍ថែមទៀតអំពីប្រវត្តិសាស្ត្រជាច្រើនបែបច្រើនយ៉ាង ដែលអ្នកនិពន្ធបានសរសេរឡើង ដូចជា ៖ ប្រវត្តិផ្នែកនយោបាយ ប្រវត្តិផ្នែកសង្គម ប្រវត្តិផ្នែកសេដ្ឋកិច្ច ប្រវត្តិសាស្ត្រជាតិ ប្រវត្តិថ្នាក់មូលដ្ឋាន ប្រវត្តិសាស្ត្រពិភពលោក ប្រវត្តិផ្នែកវប្បធម៌ ។ល ។ ភាគច្រើន ខ្ញុំពិនិត្យមើលប្រវត្តិសាស្ត្រផ្នែកនយោបាយ

[១] ឧទាហរណ៍ៈ សូមមើល Laura Summers and Justin Corfield, *Historical Dictionary of Cambodia*, 2nd Ed. Oxford: Scarecrow Press, forthcoming, or Laura Summers, "The Sources of Economic Grievance in Sihanouk's Cambodia," *Southeast Asian Journal of Social Science* 14:1 (1986) 16-33 and "The CPK: Secret Vanguard of Pol Pot's Revolution," *Journal of Communist Studies* 3:2 (1987) 4-18.

ពីទស្សនវិស័យ ឬ ការវិភាគកម្រិតជាតិ។ វិធីសាស្ត្របៀបនេះក៏ត្រូវបានប្រើប្រាស់ដែរនៅក្នុងសៀវភៅ *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*[២] ។

ថ្ងៃនេះ និងក៏ជាលំហាត់មួយដែរ ខ្ញុំស្នើសុំថា យើងទាំងអស់គ្នា រួមគ្នា ប្រើប្រាស់របៀបសិក្សាមួយខុសប្លែកពីមុន និង ព្យាយាមពិនិត្យមើលប្រវត្តិសាស្ត្រតាមរយៈការធ្វើវិភាគពីថ្នាក់មូលដ្ឋាន ឬ ថ្នាក់ខេត្ត។ ឯកសាររបស់យើងគឺជារូបថតមួយចំនួនដែលថតនៅក្នុង និង ជុំវិញខេត្តប៉ៃលិន នៅក្នុងខែមេសា ឆ្នាំ១៩៩២ ។ គំនិតធ្វើការដកពិសោធន៍តាមរយៈការប្រើប្រាស់ឯកសារជារូបភាពនេះ គឺចេញមកពីសៀវភៅរបស់លោក ឌី ខាំបូលី។[៣] "រដ្ឋបាល" ភូមិភាគរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលមានរៀបរាប់នៅក្នុងជំពូក៥ គឺបានកើតឡើងសន្សឹមៗ នៅក្នុងអំឡុងសង្គ្រាមពីឆ្នាំ១៩៧០ដល់ ១៩៧៥ ជាពេលដែលរណសិរ្សរួបរួមជាតិកម្ពុជា (National United Front of Kampuchea (FUNK)) កំពុងកសាងកងទ័ពរបស់ខ្លួន។ កាលពីដំបូង ភូមិភាគគឺជាការប្រមូលផ្តុំនូវតំបន់យោធាមួយចំនួន។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ តំបន់ទាំងនេះបានត្រូវបានបញ្ចូលគ្នា បង្កើតជាភូមិភាគគ្រប់គ្រង ការពារ និង ឃ្លាំមើលសភាពការណ៍។ មេបញ្ជាការនៅអំឡុងពេលសង្គ្រាមជាច្រើននាក់ ក៏ធ្លាប់ជាលេខាបក្ស ឬ អនុលេខាបក្សកុម្មុយនីស្ត នៅតាមភូមិភាគ តំបន់ ស្រុក និង សហករណ៍។ អ្នកគ្រប់គ្រងនៅតាមខេត្ត ជាធម្មតា ទទួលខុសត្រូវលើសេវាសាធារណៈជាច្រើន ដែលរួមមានទាំង សាលារៀន ការពារសណ្តាប់ធ្នាប់ តុលាការ និង មន្ទីរពេទ្យ។ ដោយមិនយកចិត្តទុកដាក់ចំពោះ ការគ្រប់គ្រងតាមខេត្ត និង រដ្ឋ និង បានផ្តល់អំណាចខ្លាំងទៅយោធាកម្ពុជាប្រជាធិបតេយ្យបានបង្កើត ជារបបមួយដែលគ្រប់គ្រងដោយ យោធា និង ឃ្លាំមើលសភាពការណ៍។

ស្រដៀងគ្នានេះដែរ ធាតុផ្សំសំខាន់នៃសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន សហករណ៍ ការកំណត់របបហូបចុក ការលះបង់ដើម្បីសមរភូមិ ត្រូវបានដាក់ឲ្យដំណើរការមកដល់ត្រឹម ចុងឆ្នាំ១៩៧៣ ។ ការប្រើប្រាស់លុយត្រូវបានហាមឃាត់នៅតាមថ្នាក់មូលដ្ឋានមួយចំនួន នៅក្នុង ឆ្នាំ១៩៧៤ និង បរាជ័យក្នុងការព័ទ្ធយកខេត្តកំពង់ចាម បានជំរុញឲ្យមានការជម្លៀសប្រជាជនចេញពី ទីប្រជុំជនខ្លះនៅក្នុងឆ្នាំដដែលនេះ។ គិតមកដល់ត្រឹមឆ្នាំ១៩៧៥ ប្រជាជន"មូលដ្ឋាន"មានចរិតសង្ស័យ និងខឹងសម្បាចំពោះប្រជាជន"ថ្មី" ។ ការលំបាកវេទនាដែលកើតចេញពីការតស៊ូវណ្ណៈមិនមានគ្រោងទុក ជាមុននៅក្នុងចំណោមប្រជាជាតិខ្មែរនេះ បានធ្វើឲ្យចុះថយនូវជំនឿចិត្តទៅលើបដិវត្តកុម្មុយនីស្ត ។ នៅក្នុង បរិបទនៃការញាំញីដោយសង្គ្រាមនេះ ការលេចចេញនូវសេចក្តីព្រាងផែនការបួនឆ្នាំរបស់កម្ពុជា-

[២] ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*, ភ្នំពេញៈ មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពឆ្នាំ២០០៧ ។

[៣] សូមមើលហ្វុតណូត លេខ២, ទំព័រ ២៤-២៨ ។

ប្រជាធិបតេយ្យ ដែលត្រូវបានពិភាក្សាយ៉ាងប្រញាប់ប្រញាល់ និង បន្ទាប់មក ត្រូវគេព្រងើយកន្តើយនោះ ហាក់បីដូចជាសម្បទានមួយទៅឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនតូចដែលជឿថា ការដាក់ផែនការគឺជាការចាំបាច់ និង អាចធ្វើទៅរួច ។[៤] ការរៀបចំផែនការ គឺមិនមែនត្រឹមតែជារឿងដាក់កម្រិតណាមួយតម្រូវឲ្យប្រជាជនត្រូវតែសម្រេចឲ្យបាននោះទេ ។ នៅក្នុងសេដ្ឋកិច្ចសង្គមនិយម រដ្ឋជាអ្នកគ្រប់គ្រងលើធនធានថវិកាដែលត្រូវបានបែងចែកយ៉ាងប្រុងប្រយ័ត្ន ទៅលើវិស័យកសិកម្ម ឧស្សាហកម្ម គមនាគមន៍ និង សុខភាពសាធារណៈ ។ បន្ទាប់មក រដ្ឋគណនាអំពីបរិមាណផលិតផលអាហារដែលនឹងទទួលបាន តាមរយៈធនធានដែលមាន (ឧទាហរណ៍ ដី គ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វល្អិត ប្រេង) ចំនួនម៉ោងធ្វើការ ផលិតផលក្នុងមួយហិកតារ និង សមត្ថភាពក្នុងការដឹកជញ្ជូន (ចាំបាច់ណាស់សម្រាប់ ចែកចាយធនធាន និងសម្រាប់ប្រមូល ចម្រាញ់ ចែកចាយបន្ត ឬដោះដូរផលិតផល) ។ ការរៀបចំផែនការរដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមិនសូវល្អ ប៉ុន្តែការអត់ឃ្លានគឺបណ្តាលមកពីការរើសអើងនយោបាយទៅលើប្រជាជនថ្មី និងប្រជាជន «បញ្ញើ» នៅក្នុងប្រព័ន្ធផ្តល់របបអាហារ ការគ្រប់គ្រងមិនត្រឹមត្រូវលើវិស័យកសិកម្ម និងឧស្សាហម្ម និងការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ទៅលើសុខភាព ។ ការស្លាប់ដែលបណ្តាលមកពីឥទ្ធិពលរួមដោយការធ្វើការបាក់កម្លាំង ជំងឺ និង ការអត់ឃ្លាន គឺមានចំនួនច្រើនជាងការស្លាប់ ដោយសារការបោសសម្អាត ការសម្លាប់រង្គាល និង ជម្លោះតាមព្រំដែន ឆ្ងាយណាស់ ។

ប្រវត្តិរបស់ខេត្តប៉ៃលិនពីឆ្នាំ១៩៩២ ដល់ ១៩៩៦ គួរឲ្យចាប់អារម្មណ៍ណាស់ ព្រោះយើងអាចអង្កេតមើលរបៀបដែលកងពលនៅក្នុងកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ (National Army of Democratic Kampuchea (NADK)) ចាប់ផ្តើមទទួលស្គាល់ និង ដោះស្រាយបញ្ហាខ្វះខាតការគ្រប់គ្រងរដ្ឋបាល និង សេដ្ឋកិច្ចសង្គ្រាម ។ រឿងនេះចាប់ផ្តើមនៅដើមឆ្នាំ១៩៩២ នៅពេលដែលកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យដណ្តើមបានការកាន់កាប់ទីក្រុងមួយគ្មានមនុស្សរស់នៅ និងត្រូវបានបញ្ជាឲ្យប្រែក្លាយក្រុងនេះជា«រដ្ឋធានី»សម្រាប់ការប្រើប្រាស់របស់ស្តេចដែលជាប្រមុខរដ្ឋ និង មន្ត្រីផ្សេងៗទៀតនៃរដ្ឋាភិបាលជាតិកម្ពុជា (National Government of Kampuchea (NADK)) (១៩៩០ - ១៩៩៣) ។ កាលពីដើមឆ្នាំ១៩៩២ គណៈប្រតិភូពីគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និង មន្ត្រីអង្គការសហប្រជាជាតិ បានធ្វើទស្សនកិច្ចទៅកាន់ប៉ៃលិន ។ អ្នកខាងក្រៅបានចាប់ផ្តើមមើលឃើញថា ប៉ៃលិនជាកន្លែងនយោបាយសំខាន់មួយ បើទោះបីជាវាគ្រាន់តែជាភូមិភាគយោធាមួយ និងជាក្រុងមួយគ្មានមនុស្សរស់នៅក៏ដោយ ។

---

[៤] សូមមើលសៀវភៅ David Chandler, Chanthou Boua and Ben Kiernan, editors and translators. *Pol Pot Plans the Future: Confidential Leadership Documents from Democratic Kampuchea, 1976-1977*. New Haven: Yale University Southeast Asia Studies Council Monograph No. 33, 1988.

[ចាប់ផ្តើមបង្ហាញរូបថតៈ]

*រូបថត ១ (ផែនទីផ្លូវខេត្តច័ន្ទបុរី)៖ ប៉ៃលិនជា«ក្រុង»មួយនៅជាប់ព្រំដែនខេត្តច័ន្ទបុរី ។ ខេត្តមួយទៀតមិនមានឈ្មោះទេ ។ ផែនទីនេះមិនបានបញ្ជាក់ថា ខេត្តមួយទៀតជាខេត្តបាត់ដំបង ឬថា ខេត្តបាត់ដំបងជាខេត្តមួយនៅក្នុងរដ្ឋកម្ពុជាទេ (*State of Cambodia (SOC)*) ។ អ្នកជាតិនិយមសូមចាប់អារម្មណ៍នៅទីនេះ! ផែនទីផ្លូវនេះគឺត្រូវបានផលិតឡើងដោយសណ្ឋាគារថៃមួយនៅក្បែរព្រំដែន ។ ផែនទីនេះមិនមែនបង្ហាញអំពីផែនការរបស់រដ្ឋាភិបាលថៃ ក្នុងការភ្ជាប់ខេត្តបាត់ដំបងទៅក្នុងទឹកដីថៃជាលើកទីបីនោះទេ ។ បុគ្គលិកសណ្ឋាគារបាននិយាយថា ពួកគេគាំទ្រឲ្យកែប្រែ«សមរភូមិឲ្យទៅជាទីផ្សារ» ។ ពួកគេដឹងច្បាស់ថា កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ (*NADK*) គ្រប់គ្រងប៉ៃលិន ។ ពួកគេមិនបានដឹងថា ប៉ៃលិននៅពេលនោះមិនមានមនុស្សទេ ។*

*រូបថត ២ (ប៉ៃលិននៅក្នុងភាពខ្ទេចខ្ទាំ «ក»)៖ ប៉ៃលិនត្រូវបានកាន់កាប់ដោយកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ (*NADK*) មិនយូរប៉ុន្មានបន្ទាប់ពីកងទ័ពវៀតណាមបានចាកចេញពីក្រុងនេះនៅក្នុងឆ្នាំ១៩៨៩ ។ កងទ័ពរដ្ឋកម្ពុជាដណ្តើមតំបន់នេះកាន់កាប់ម្តងទៀតបានមួយរយៈពេលខ្លី ប៉ុន្តែ កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យដណ្តើមបានវិញ នៅចុងឆ្នាំ១៩៩១ ។ កងទ័ពកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមចាត់ចែងផ្ទះដែលទទួលរងការខូចខាតទៅឲ្យក្រុមគ្រួសារកងទ័ព និង មានគម្រោងបោះទីតាំងកងទ័ព និង ក្រុមគ្រួសារកងទ័ពចំនួនបីពាន់នាក់នៅទីនោះ ។ ប៉ុន្តែ ក្រុងនោះមានមនុស្សតែប្រមាណពីរបីរយនាក់ប៉ុណ្ណោះកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩២ ។ មិនមានទីផ្សារ ហើយក៏មិនមានអាជ្ញាធរស៊ីវិលដែរ ។*

*រូបថត ៣ (ប៉ៃលិននៅក្នុងភាពខ្ទេចខ្ទាំ «ខ»)៖ ផ្ទះភាគច្រើនស្ថិតនៅក្នុងសភាពខូចខាត ដែលស្ទើរតែមិនអាចរស់នៅបាន ។ ក្រុមគ្រួសាររបស់យោធាជាអ្នកជួសជុលផ្ទះទាំងនោះ ។ មេបញ្ជាការកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យបានប្រាប់ខ្ញុំថា ផ្តល់សម្ភារៈឲ្យជួសជុលផ្ទះខូចខាតគឺចំណាយអស់តិចជាងសាងសង់ផ្ទះថ្មី ។ (ពួកគេបានរៀបចំផែនការ និង ថវិកាជាមុន) ។ យើងអាចមើលឃើញថាផ្ទះនេះមានម្ចាស់រស់នៅគឺដោយសារតែទាហានបានយកខ្សែមកចងដាក់ហាលសម្លៀកបំពាក់ ។ គួរកត់-ចំណាំថា ទ្វារ ស៊ុមទ្វារ និង ឈើតាមបង្អួច គឺមិនឃើញមានទេនៅតាមផ្ទះបែកបាក់ទាំងនេះ ។*

រូបថត ៤ (ប៉ៃលិននៅក្នុងភាពខ្ទេចខ្ទាំ «គ»)៖ នៅក្នុងផ្ទះទាំងបីនេះ យើងឃើញគេកំពុងតែសម្អាតកម្ទេចកម្ទីបាក់បែកៗ នៅក្នុងផ្ទះដែលមានដំបូល មនុស្សម្នាក់កំពុងតែទទួលទានដំណេកនៅក្នុងអង្រឹង។ មានកម្រាលឥដ្ឋថ្មី និង យ៉ាងហោចណាស់ក៏មានក្មេងម្នាក់ដែរនៅទីនោះ ដោយសារយើងឃើញមានស្បែកជើងតូចៗនៅពីខាងមុខ។ ផ្ទះពីរទៀត មិនមានដំបូល និង កម្រាលទេ ប៉ុន្តែ មានឆ្នាំងបាយ និង មានផ្សែងកំពុងតែដាំស្ល។ យើងឃើញមានហាលសម្លៀកបំពាក់ផងដែរ។ យើងអាចមើលនៅខាងក្នុងផ្ទះដោយសារតែផ្ទះទាំងនោះគ្មានទ្វារ ស៊ុមទ្វារ និង ស៊ុមបង្អួច។

រូបថត ៥ (ផ្ទះទាហាននៅតាមជម្រាលភ្នំ)៖ ឈើដែលបាក់ទាំងនោះត្រូវគេយកទៅប្រើដើម្បីសាងសង់ខ្ទមដែលធ្វើពីដី។ ផ្ទះដីនេះមានទីតាំងនៅលើភ្នំយ៉ាត ចំហៀងខាងក្រោយវត្តភ្នំយ៉ាតដែលជាវត្តចំណាស់ដ៏ស្អាតរបស់ជនជាតិកុឡា។

រូបថត ៦ (វត្តភ្នំយ៉ាតថតពីខាងក្រោយ)៖ ផ្ទះដីនោះមានទីតាំងនៅពីខាងក្រោយវត្ត ដែលយើងអាចមើលទៅឃើញព្រៃឈើទាបៗ វាលខ្ពង់រាប និង ភ្នំតូចៗបន្តកន្ទុយគ្នា។ វៀតណាមបានសាងសង់ផ្ទះដីនេះនៅពេលដណ្តើមបានប៉ៃលិននៅក្នុងទសវត្សរ៍៨០ ។

រូបថត ៧ (វត្តភ្នំយ៉ាត «ក»)៖ ចំហៀងខាងនេះមិនមានការខូចខាតទេ។

រូបថត ៨ (វត្តភ្នំយ៉ាត «ខ»)៖ ចំហៀងខាងនេះមានការខូចខាតបន្តិចបន្តួច។ កម្ទេចកម្ទីនេះគឺមកពីអគារតូចមួយនៅជាប់វត្ត មិនមែនមកពីតួវត្តទេ។ នៅតាមជញ្ជាំងខាងក្នុងរបស់វត្ត មានរូបគំនូរនៅខាងក្នុង។ ការខូចខាតនេះត្រូវគេបន្ទោសថាមកពីការបាញ់គ្រាប់រ៉ុក្កែតរបស់ «វៀតណាម»។ កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យបានអះអាងថា ពួកគេមិនធ្លាប់បាញ់ប្រហារទៅលើវត្ត ឬ កំពូលភ្នំទេ។ ពួកគេជឿជាក់ថា មានបារមីការពារវត្ត និង ក្រុងនេះ នៅពេលពួកគេធ្វើការវាយប្រហារទៅលើវត្តនោះ។

រូបថត ៩ (វត្តភ្នំយ៉ាត «គ»)៖ ជណ្តើដំបូងនៃជណ្តើរដ៏វែងឡើងទៅលើភ្នំ គឺកំពុងតែទ្រុឌទ្រោម ប៉ុន្តែមិនត្រូវបានខ្ទេចខ្ទាំដោយការវាយប្រហារគ្នានោះទេ។

រូបថត ១០ (វត្តភ្នំយ៉ាត «ឃ»)៖ ជណ្តើរដំណាក់ទីពីរទទួលរងនូវការប៉ះពាល់ដោយផ្ទាល់។ បើទោះបីជា កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យមានបញ្ជាហាមមិនឲ្យបាញ់ប្រហារទៅលើវត្តនៅលើភ្នំ ឬ

បាញ់តបតទៅគ្រាប់កាំភ្លើងបាញ់ចេញពីកំពូលភ្នំក៏ដោយ លេណដ្ឋានកាំភ្លើងធំមួយត្រូវបានជីកនៅស្របគ្នា និង ផ្នែកខាងក្រោមជណ្ដើរផ្នែកនេះ ។ ពួកគេអះអាងថា ពួកគេឃើញមានការបាញ់ប្រហារចេញពីលេណដ្ឋាននេះប៉ុន្មានដងដែរ ប៉ុន្ដែ នៅពេលពួកគេបាញ់តម្រង់ទៅវិញ កាំភ្លើងរបស់ពួកគេបាញ់មិនចេញទាល់តែសោះ ។ ប៉ុន្ដែ បន្ទាប់ពី "ជ័យជម្នះ"ភ្លាមៗ ពួកគេឃើញមានការខូចខាតនៅទីនោះ ។ ពួកគេបានត្រឡប់ទៅថតរូបវត្តភ្នំយ៉ាតដើម្បីអបអរជ័យជម្នះ ប៉ុន្ដែ ម៉ាស៊ីនថតរបស់ពួកគេមិនដំណើរការសោះ ។ ពួកគេបានបន្ទោសទៅលើបារមីនៅទីនោះ ។ ប៉ុន្មានថ្ងៃបន្ទាប់មកទើបពួកគេអាចថតរូបបាន ។ យោធាទាំងនោះយល់ថា នោះគឺជាសញ្ញាបង្ហាញថា ពួកគេបានត្រូវរ៉ូវគ្នាវិញហើយ ជាមួយបារមីភ្នំយ៉ាត ។

រូបថត ១១ (វត្តភ្នំយ៉ាត "ច")៖ សាលាដំណាក់មិនបានទទួលរងខូចខាតដោយសារសង្រ្គាមទេ ។ ប៉ុន្ដែរូបគំនូរនៅលើជញ្ជាំងខាងក្នុងទទួលរងការខូចខាតខាតខ្លះដោយសារសំណើម និង ទឹក ។

រូបថត ១២ (វត្តភ្នំយ៉ាត "ឆ")៖ រូបថតនេះគឺឈឺឲ្យថតតែម្ដង ។ មិត្តភក្តិនៅទីក្រុងភ្នំពេញបានប្រាប់ជនជាតិបរទេសនេះថា វត្តភ្នំយ៉ាតត្រូវបានបំផ្លាញដោយកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ នៅពេលពួកគេដណ្ដើមបានការកាន់កាប់ជាថ្មី ។ គេប្រាប់ជនបរទេសនេះទៀតថា កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យបានអនុញ្ញាតឲ្យក្រុមហ៊ុនថៃជីករកត្បូងនៅលើភ្នំយ៉ាត និង ថា ភ្នំយ៉ាតត្រូវវិលាយអស់ហើយ ។ មេបញ្ជាការធំៗទាំងនោះថតជាមួយជនបរទេសដើម្បីបង្ហាញថា វត្តភ្នំយ៉ាតនៅទីនោះនៅឡើយ និងថាពួកគេជាអ្នកការពារកេរ្ដិ៍មរតកជាតិនៅប៉ៃលិន ។ ម៉ាស៊ីនថតទាំងអស់ដំណើរការធម្មតានៅថ្ងៃនោះ ។

រូបថត ១៣ (ភ្នំយ៉ាត "ជ")៖ ព្រះអង្គម្ចាស់ ដែលជាប្រមុខរដ្ឋនិងជាអ្នកដឹកនាំរដ្ឋាភិបាលជាតិនៃកម្ពុជា (National Government of Kampuchea) (១៩៩០-១៩៩៣) បានធ្វើទស្សនកិច្ចមកកាន់ប៉ៃលិន និងបានទទួលភ្ញៀវអគ្គរដ្ឋទូតបរទេសនៅទីនោះ ។ ដើម្បីទទួលព្រះអង្គម្ចាស់ឲ្យបានសមរម្យ ប៉ៃលិនត្រូវតែរៀបចំកែតម្រូវ ។ ប៉ៃលិន ត្រូវតែមើលទៅឲ្យសមរម្យជាទីក្រុង ហើយវាត្រូវតែមានលក្ខណៈសំគាល់ជារាជធានី ។ ក្នុងរយៈពេលពីរសប្ដាហ៍ និង ត្រូវធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ យោធាចំនួនបីពាន់នាក់ជាមួយម៉ាស៊ីនឈូសឆាយដី និង ឧបករណ៍សាងសង់ផ្សេងៗ ចាប់ផ្ដើមបោសសម្អាតការខូចខាតដោយសារសង្រ្គាម និង សំរាមចេញពីផ្ទះដែលបាក់បែកទាំងនោះ ។ ការងាររជួសជុលដែលស្មុគស្មាញខ្លះនៅក្បែរផ្លូវចូលវត្តភ្នំយ៉ាតត្រូវបានពន្យារពេលសិន ប៉ុន្ដែ បំណែកផ្សេងៗត្រូវបានរៀបចំប្រមូលទុកសម្រាប់អ្នកជំនាញនៅពេលក្រោយ ។

រូបថត ១៤ (ទីប្រជុំជនប៉ៃលិន ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩២)៖ ទង់ជាតិពណ៌ខៀវសដែលកំពុងតែបក់នេះ ជាទង់ជាតិកម្ពុជា ដែលកាលពីមុនហៅថា កម្ពុជាប្រជាធិបតេយ្យ ។ ទង់ជាតិនេះមានផែនទីកម្ពុជាពណ៌សនៅលើផ្ទៃពណ៌ខៀវ ។ មិនឃើញមានអង្គរវត្តទេ ។ វាគឺជាទង់ជាតិរដ្ឋដំបូងបំផុតនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជា ដែលមិនមានប្រាសាទអង្គរវត្តនៅក្នុងនោះ ។ ទង់ជាតិនេះត្រូវបានប្រើប្រាស់ជំនួសទង់ជាតិកម្ពុជាប្រជាធិបតេយ្យ (១៩៧៦-១៩៩០) ដែលមានរូបប្រាសាទអង្គរវត្តពណ៌មាសកំពូលបី ។ សូមចំណាំបរវេណជុំវិញ និង ឥដ្ឋការូ ដែលប្រើប្រាស់ជាផ្លូវសម្រាប់ដើរនៅជុំវិញដងទង់ជាតិ ។ នេះបង្ហាញឃើញថា ប៉ៃលិនជាកន្លែងមួយសមរម្យដូចក្រុងដទៃទៀតដែរ ។

រូបថត ១៥ (ផ្ទះរបស់ព្រះបាទនរោត្តមសីហនុ)៖ ដងទង់ជាតិ និង សួនច្បារនេះ គឺស្ថិតនៅចំពីមុខគេហដ្ឋានដ៏ទំនើបស្អាតរបស់ព្រះបាទនរោត្តមសីហនុ ។ ផ្ទះនេះទើបតែគូបតែងលំអ និង លាបថ្នាំថ្មីៗនៅមុនពេលទស្សនកិច្ចរបស់ព្រះអង្គម្ចាស់ប្រមុខរដ្ឋ ។ គ្រឿងសង្ហារិមនៅក្នុងផ្ទះនេះត្រូវបានជួលរយៈពេលមួយសប្តាហ៍ ហើយទាំងអស់នេះគឺជួលពីផ្ទះថៃខត្តមសេនីយ៍មួយរូប ។ គ្រឿងសង្ហារិមទាំងនេះត្រូវបានគេរៀបរាប់ថា“ស្អាតណាស់” ។ (ប្រពន្ធរបស់ឧត្តមសេនីយ៍ថៃនោះមិនសប្បាយចិត្តទេ ប៉ុន្តែយល់ស្របទៅនឹងការជួលនោះ) ។ រហូតមកដល់ខែកុម្ភៈ ឆ្នាំ១៩៩២ ផ្ទះនេះគឺជាបញ្ជាការដ្ឋានរបស់អគ្គសេនាធិការកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ។ ទាំងសុន សេន និង តាម៉ុក ធ្លាប់ធ្វើការនៅក្នុងផ្ទះនេះ ។

រូបថត ១៦ (ផ្ទះអ៊ុនតាក់)៖ នៅក្បែរអតីតអគារអគ្គសេនាធិការ កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ បានរៀបចំផ្ទះមួយសម្រាប់អ៊ុនតាក់ ។ ក្រុមការងាររដ្ឋមុខរបស់អ៊ុនតាក់ធ្លាប់ធ្វើទស្សនកិច្ចម្តង ឬពីរដងរួចមកហើយ ប៉ុន្តែ បញ្ជាការដ្ឋាននេះមិនទាន់ប្រើប្រាស់ពេញលេញនៅឡើយ ។ សូមកត់សំគាល់ថា អគារនេះហាក់បីដូចជាមានខ្សែភ្លើងថ្មី និងមានផ្លូវចូលចាក់ស៊ីម៉ង់ត៍ថ្មី ។

រូបថត ១៧ (ទីប្រជុំជនប៉ៃលិន)៖ ការប្រែក្លាយប៉ៃលិនពីតំបន់សមរភូមិទៅជាតំបន់ទីប្រជុំជនតម្រូវឲ្យមានការពង្រីក និង កែលម្អផ្លូវជាច្រើននៅក្នុងទីក្រុង ។ ផ្ទះនៅខាងស្តាំត្រូវបានគេប្រាប់ថាជាផ្ទះឯកជន ។ ផ្ទះនេះកំពុងត្រូវគេកែប្រែធ្វើជាសណ្ឋាគារ មានបីបន្ទប់ និង ជាន់ផ្ទាល់ដីជាហាងកាហ្វេ ។ ហាងកាច់ជ្រុងនៅខាងឆ្វេងមានលក់គុយទាវ ។ ហាងផ្សេងទៀតគឺមានតែឱសថស្ថានតូចមួយប៉ុណ្ណោះ ។

រូបថត ១៨ (រោងភាពយន្តចាស់)៖ រោងភាពយន្តចំណាស់ដ៏អស្ចារ្យនេះមិនមានគេប្រើប្រាស់ទេ ប៉ុន្តែដោយសារវាស្ថិតនៅក្នុងទីប្រជុំជន ដែលភ្ញៀវសំខាន់ៗទាំងអស់អាចមើលឃើញនៅពេលទៅដល់ប៉ៃលិន រោងភាពយន្តនេះត្រូវបានគេបោសសម្អាត និង លាបថ្នាំថ្មី ។

រូបថត ១៩ (ប៉ុស្តិ៍ត្រួតពិនិត្យ)៖ នៅមានសញ្ញាមួយយ៉ាងច្បាស់ដែលបញ្ជាក់ថា ប៉ៃលិននៅតែជាទីបញ្ជាការដ្ឋានរបស់កងទ័ព និងមិនទាន់ជាទីក្រុង ឬ ខេត្ត នៅឡើយ ។ បុរសទាំងពីរនេះឈរយាមប៉ុស្តិ៍ត្រួតពិនិត្យដែលលោក យ៉ាស៊ូស៊ី អាកាស៊ី អះអាងថាបានរារាំងមិនឲ្យគាត់ចូលទៅកាន់ទីក្រុង ។ សូមចាប់អារម្មណ៍ទៅលើក្រុមកងទ័ពរដ្ឋាភិបាលជាតិ ។

រូបថត ២០ (ចំណតឧទ្ធម្ភាគចក្រ)៖ កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យបានសាងសង់កន្លែងចំណតឧទ្ធម្ភាគចក្រ ជាមួយនឹងបន្ទប់ទទួលទានភោជនាហារសម្រាប់ទទួលភ្ញៀវកិត្តិយស ជាពិសេសឯកអគ្គរដ្ឋទូតដែលនឹងត្រូវទទួលដោយព្រះបាទនរោត្តមសីហនុព្រះប្រមុខរដ្ឋ ។ គណៈប្រតិភូកាកបាទក្រហមអន្តរជាតិ បានធ្វើដំណើរមកដោយរថយន្ត ដែលត្រូវចំណាយពេលអស់១០ម៉ោងពីខេត្តបាត់ដំបង ។

រូបថត ២១ (ត្រាក់ទ័រម៉ាកហ្វដ)៖ ឧបករណ៍សាងសង់ខ្លះជាកម្មសិទ្ធិរបស់កងទ័ពជាតិកម្ពុជាប្រជាធិប-តេយ្យ ត្រូវបានប្រើប្រាស់សម្រាប់កែលម្អក្រុងប៉ៃលិន នៅមានសល់នៅឡើយ ។ គេនិយាយថាត្រាក់ទ័រនេះ«ថ្លៃណាស់» ។ ត្រាក់ទ័រចតនៅទីនេះបណ្ដោះអាសន្នសិន ។ នង្គ័លសម្រាប់ព្យួរនៅភ្ជាប់ពីក្រោយ ។

រូបថត ២២ (រណ្ដៅខ្សាច់)៖ កុមារតូចៗលេងនៅក្នុងដីខ្សាច់នេះ ប៉ុន្តែ វាច្បាស់ណាស់ថា ដីខ្សាច់នេះមិនយូរប៉ុន្មានទេនឹងត្រូវធ្វើជាស៊ីម៉ង់ត៍ ។ បុរសនៅឈរពីខាងក្រោយ ប្រហែលជាឪពុករបស់កុមារនោះគឺជាសមាជិកម្នាក់នៃក្រុមកងទ័ពទទួលខុសត្រូវចំពោះការផ្សារទឹក និង លូនៅប៉ៃលិន ។

រូបថត ២៣ (ជ្រូក)៖ ជ្រូកមេសម្រាប់បង្កាត់ពូជដ៏ធំនេះ បានប្រើងប្រែងសម្អាតសំរាមពីតាមចិញ្ចើមផ្លូវ ។ ប៉ៃលិនកមានមាន់ខ្មៅដើររហេតរហូតយ៉ាងមានសេរីភាព ។ គ្រួសារមួយមានសត្វឆ្កែមួយក្បាលប្រហែលជាសម្រាប់ដេញសត្វ ។ ឆ្កែនោះដើរតាមខ្ញុំ នៅពេលខ្ញុំដើរលេងនៅពេលព្រលឹមស្រាងៗ ។ ស្ត្រីម្នាក់បានប្រាប់ឲ្យប្ដីរបស់គាត់«តាមឆ្កែដែលដើរតាមបារាំង» ព្រោះឆ្កែនោះជារបស់ពួកគេ ។

រូបថត ២៤ (រោងដាក់កាហ្វេ)៖ នៅក្នុងទសវត្សរ៍៦០ ប៉ៃលិនមានឈ្មោះល្បីល្បាញណាស់ចំពោះចម្ការផ្លែឈើ និង ចម្ការកាហ្វេ។ ចម្ការស្ថិតនៅក្នុងសភាពបំផ្លិចបំផ្លាញនៅក្នុងឆ្នាំ១៩៩២ ។ កងទ័ពវៀតណាមកាន់កាប់ប៉ៃលិនចាប់ពីខែមករា ឆ្នាំ១៩៨០ រហូតដល់ខែតុលា ឆ្នាំ១៩៨៩ និងបានប្រើប្រាស់រោងដាក់កាហ្វេធ្វើឃ្លាំងគ្រាប់ខាងលិចរបស់ខ្លួន។ សំបកគ្រាប់នេះគឺទទេមិនមានអ្វីទេ។

រូបថត ២៥ (របៀបផលិតកាហ្វេ)៖ កន្លែងហាលសម្ងួត ឧបករណ៍សម្រាប់ផលិតកាហ្វេ និង ពាងទឹកធំមួយនេះ ត្រូវបានគេបោះបង់ចោលឡើងកាន់ព្រៃ។ នៅក្នុងរូបថតនេះ កម្មាភិបាលកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ កំពុងត្រួតពិនិត្យមើលកន្លែងបោះបង់ចោលនោះ។ ពួកគេនិយាយថា ឧបករណ៍ទាំងនោះចាស់ពេក មិនអាចប្រើប្រាស់បានទេ។ ពួកគេមិនមានគម្រោងការណាមួយនឹងប្រើប្រាស់ចំការនេះឡើងវិញ ឬ ប្រើប្រាស់ដីចំការនោះនៅក្នុងពេលឆាប់ៗនោះទេ។ ពួកគេនិយាយថា គ្រាប់មីនត្រូវបានគេដាក់នៅរាយប៉ាយជុំវិញតំបន់នេះ ដើម្បីការពារឃ្លាំងគ្រាប់ ។

រូបថត ២៦ (សត្វគោ)៖ ប៉ៃលិនមិនមានទីផ្សារ និង ទឹកម៉ាស៊ីនទេ។ ម្ហូបអាហារទាំងអស់ត្រូវនាំចូលទៅកាន់តំបន់នោះ។ ទឹកប្រើប្រាស់ត្រូវយួរពីអណ្តូងនៅជាយក្រុង។ កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យទិញសត្វគោភ្លាមៗពីប្រទេសថៃ។ ហ្វូងគោនេះនឹងត្រូវគេកាប់សាច់ នៅពេលប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ តែប៉ុន្មានថ្ងៃក្រោយមកទៀតប៉ុណ្ណោះ។

រូបថត ២៧ (ផ្ទះថ្មី និង ចម្ការ «ក»)៖ គ្រួសារជាច្រើនដែលចង់ធ្វើចម្ការជាជាងរស់នៅក្នុងទីប្រជុំជនទទួលបានចំណែកដីចំនួនពីរហិកតា និង ជំនួយផ្សេងទៀតក្នុងការសាងសង់ផ្ទះថ្មី។ នេះគឺផែនការមួយក្នុងការផលិតអង្ករ និង អាហារផ្សេងៗទៀត។ នៅក្នុងរូបនេះគឺជារដូវដាំដុះដំបូងបំផុត។

រូបថត ២៨ (ផ្ទះថ្មី និង ចម្ការ «ខ»)៖ អ្នកតាំងទីលំនៅថ្មីៗខ្លះគឺជាទាហានរំសាយ។ អ្នកខ្លះទៀតជាអតីតឈ្លើយសឹកដែលបានរៀបការជាមួយនារីនៅទីនោះ ឬ ក៏ជាស្ត្រីមេម៉ាយដោយសារប្តីរបស់ខ្លួនជាកងទ័ពកម្ពុជាប្រជាធិបតេយ្យដែលស្លាប់ទៅ។ ស្ត្រីនៅតំបន់នោះជាអ្នកផ្តល់អាហារឲ្យបុរសកាលពីពេលនៅជាអ្នកទោស។

*រូបថត ២៩ (វត្តមណ្ឌល)៖ វត្តមណ្ឌលជាវត្តពុទ្ធសាសនាមហានិកាយធំបំផុតនៅប៉ៃលិន ។ វត្តនេះមានការតុបតែងរចនាយ៉ាងសម្បើម ។ គេនិយាយថា មានព្រះសង្ឃបានវិលត្រឡប់ទៅកាន់វត្តនេះដើម្បីបំពេញកិច្ចការ និង សិក្សានៅទីនោះវិញហើយ (ប៉ុន្តែ នៅក្នុងរូបនេះ មិនឃើញមានព្រះសង្ឃទេ) ។ ស្ត្រី និង មនុស្សចំណាស់ខ្លះ បានមកកាន់ទីនោះ ដើម្បីរៀបចំប្រារព្ធពិធីចូលឆ្នាំថ្មី ។ មនុស្សម្នាក់បាននិយាយថា គាត់គិតថា ព្រះសង្ឃនឹងរៀបចំបើកសាលារៀនឡើងវិញ ។ មេបញ្ជាការកងទ័ពកម្ពុជាប្រជាធិបតេយ្យម្នាក់បាននិយាយថា ពួកគេមិនទាន់ព្រមព្រៀងគ្នាក្នុងការបើកសាលារៀននៅឡើយទេ ។ គាត់ហាក់ដូចជាចង់ឲ្យមានសាលារៀន«រដ្ឋ»ច្រើនជាង (ប៉ុន្តែ មិនមានអាជ្ញាធរក្រុងទេ ហើយក៏គ្មានប្រព័ន្ធសាលារដ្ឋដែរនៅក្នុងកម្ពុជារបស់គាត់) ។*

*រូបថត ៣០ (ផ្លូវគ្រប់រដូវ)៖ ផ្លូវចូលទៅក្នុង និង ជុំវិញក្រុង កំពុងត្រូវបានកែលម្អទៅជាផ្លូវគ្រប់រដូវ ។ ផ្លូវមួយនេះត្រូវបានធ្វើឡើងដោយក្រុមហ៊ុនថៃ ជាថ្នូរដោយផ្នែក ទៅនឹងសិទ្ធិចូលទៅកាន់តំបន់រ៉ែត្បូង ។ មិនមានការដោះដូរលុយកាក់ទេ នៅក្នុងកិច្ចព្រមព្រៀងធ្វើហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ។ ការចំណាយផ្សេងៗ ធ្វើឡើងដោយការប្រើប្រាស់លុយបាតរបស់ថៃ ។*

*រូបថត ៣១ (រថក្រោះ«វៀតណាម»)៖ រថក្រោះនេះលែងប្រើប្រាស់នៅក្នុងទសវត្សរ៍៨០ ។ រថក្រោះនេះត្រូវបានគេយកចេញពីក្បែរផ្លូវសំខាន់មួយទៅកាន់ប្រទេសថៃ ពេលនោះមានកិច្ចព្រមព្រៀងឈប់បាញ់ រថក្រោះនោះលែងមានប្រយោជន៍ ហើយមិនមាននរណាម្នាក់ចង់ដាក់បង្ហាញវានៅក្នុងទីក្រុងទេ ។*

*រូបថត ៣២ (រូបសំណាកសត្វព្រាបទំលើផែនដី)៖ ព្រាបសមានពាំសំបុត្រនៅនឹងចំពុះរបស់វាទំនៅលើរូបផែនដី នៅក្នុងសួនច្បារតូចមួយនៅទីប្រជុំជនប៉ៃលិន ។ ច្បាស់ណាស់នេះគឺតំណាងឲ្យគំនិតដែលថា ប្រជាជាតិទាំងឡាយគួរតែចាប់ដៃគ្នា ។ មិនមាននរណាម្នាក់អាចពន្យល់ប្រាប់ខ្ញុំបានទេថា នរណាជាអ្នកធ្វើរូបសំណាកនេះឡើង ឬ សាងសង់ពីពេលណាមកទេ ។ រូបសំណាកនេះនៅទីនោះតែម្តង ។ មេបញ្ជាការទាំងនោះនិយាយថា រូបសំណាកនេះជាកម្មសិទ្ធិរបស់ប៉ៃលិន ដូច្នេះហើយបានជាវានៅទីនោះ ។ រូបសំណាកនេះនឹងត្រូវថែរក្សាទុកនៅទីនោះ ។*

*សេចក្តីសន្និដ្ឋាន៖*

សម្រាប់កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ជីវិតបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ផ្តើមជាផ្លូវការនៅក្នុងឆ្នាំ១៩៩០ នៅពេលដែលរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានក្លាយជារដ្ឋាភិបាលជាតិនៃកម្ពុជា ។ សេដ្ឋកិច្ចចាំបាច់តម្រូវឲ្យមានការធ្វើសេរីភាវូនីយកម្ម នៅពេលដែលជំនួយរបស់ប្រទេសចិនត្រូវបញ្ចប់ (ក្នុងឆ្នាំ១៩៩០) ។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស តម្រូវការនយោបាយមិនបានគ្រោងទុកជាមុនមួយចំនួនធំបានក្លាយទៅជាបន្ទុករបស់មេបញ្ជាការកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅប៉ៃលិន ដែលបានសម្រេចកសាងទីក្រុងឡើងវិញ និង ធ្វើឲ្យសេដ្ឋកិច្ចទទួលផលច្រើនជាងមុន ។ ប្រាក់ចំណូលពីរ៉ែត្បូង«មិនគ្រប់គ្រាន់ទេ» ។ ឧបករណ៍ដោះមីនចំណាយ «ថ្លៃណាស់» ។ ម្ហូបអាហារទាំងអស់សុទ្ធតែត្រូវនាំចូល ដូច្នេះ ត្រូវតែផលិតអាហារ ។ យ៉ាងហោចណាស់ក៏នៅដើមឆ្នាំ១៩៩២ដែរ កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅប៉ៃលិនបានរៀបចំគម្រោងបង្កើតសហគ្រាសឯកជនដែលគ្រប់គ្រងជារួម ពោលគឺក្រុមហ៊ុនដែលជាកម្មសិទ្ធិរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ គ្រប់គ្រងប្រកបដោយឯករាជ្យ និងវិជ្ជាជីវៈ ។ មានការពិភាក្សាអំពីការកសាងស្ថានីយផ្គត់ផ្គង់ភ្លើងអគ្គិសនី និង អំពីការបង្កើតជាក្រុមហ៊ុនអគ្គិសនី ។ ម៉ាស៊ីនភ្លើងមានតម្លៃ«ថ្លៃពេក» និងបង្ករសំឡេងរំខានខ្លាំងសម្រាប់អ្នករស់នៅក្នុងទីក្រុង ។ ការបង្កើតជាក្រុមហ៊ុនអគ្គិសនីនឹងជំរុញដល់ការផ្ទេរជំនាញយោធាមកប្រើប្រាស់នៅក្នុងការអភិវឌ្ឍខ្សែរាហកម្ម ។

កងទ័ពបានបះបោរ នៅក្នុងឆ្នាំ១៩៩៦ នៅពេលដែលកងទ័ពកម្ពុជាប្រជាធិបតេយ្យប៉ៃលិនត្រូវបានស្នើសុំឲ្យធ្វើជាតួបនីយកម្មម្តងទៀតនូវទ្រព្យសម្បត្តិឯកជនដែលរួមទាំងចម្ការថ្មីៗ ផ្ទះដែលជួសជុលរួច និង កង់ឯកជន ។ អៀង សារី បានដឹកនាំការបះបោរមួយដែលរួមមានមនុស្សប្រមាណពី ២-៣ម៉ឺននាក់ ។ មានរបាយការណ៍រួចហើយកាលពីដើមឆ្នាំ១៩៩២ថា គាត់បានគាំទ្រឲ្យមានការបង្កើតគណបក្សមួយថ្មី និងថា គាត់មានភាពឯកាខាងនយោបាយដោយសារតែរឿងនេះ ។ យ៉ាងហោចណាស់នៅដើមឆ្នាំ១៩៨១ អៀង សារីបានអះអាងថា កម្ពុជាប្រជាធិបតេយ្យ«...មិនអាចអនុវត្តឡើងវិញនូវគោលនយោបាយពីឆ្នាំ១៩៧៥-១៩៧៨»ទៀតទេ ។ គេដឹងថា គាត់ជាអ្នកគ្រប់គ្រងថវិកានៅចុងទសវត្សរ៍៨០ និង ដើមទសវត្សរ៍៩០ ។

ចលនាសហភាពជាតិប្រជាធិបតេយ្យ (The Democratic National Union Movement) បង្កើតឡើងនៅក្នុងឆ្នាំ១៩៩៦ បានបង្កើតជាអាជ្ញាធររដ្ឋបាលស៊ីវិលគ្រប់គ្រងនៅប៉ៃលិនយ៉ាងឆាប់រហ័ស ។ ទីក្រុងនេះត្រូវបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា និងត្រូវបានទទួលតំណែងជាខេត្តមួយនៅក្នុងឆ្នាំ១៩៩៧ ។ ប្រវត្តិសាស្រ្តប៉ៃលិនដែលបានសរសេររួច ឬដែលនឹងត្រូវគេសរសេរឡើង នឹងប្រហែលជាផ្តោតទៅលើរយៈពេលខ្លីមុនពេលមានការបះបោរ និងរយៈពេលភ្លាមៗបន្ទាប់ពីនោះមក ដែលជាការចរចាមិនបានសម្រេចជាមួយខាងអន្លង់វែង ។ ខ្ញុំគិតថា អ្នក

ប្រវត្តិសាស្ត្រមិនគួរមើលរំលងការផ្លាស់ប្តូរនូវការយល់ដឹងនយោបាយ និងការរៀបចំសេដ្ឋកិច្ចនៅក្នុងរយៈពេលបួនឆ្នាំមុនការបះបោរទេ ។ ទន្ទឹមនឹងពេលដែលប៉ៃលិនត្រូវបានកសាង និងរៀបចំឡើងវិញ កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅប៉ៃលិនមានមោទនភាពចំពោះទីក្រុងរបស់ពួកគេណាស់ ។ បើទោះបីជាលក្ខខណ្ឌលំបាកយ៉ាងណាក៏ដោយ គ្រួសារជាច្រើនមានជីវភាពល្អប្រសើជាងមុន ។ ខ្ញុំមិនដឹងថាមានផែនការណាមួយនោះទេ ប៉ុន្តែមានការរៀបចំផែនការ ការរៀបចំថវិកា និងការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នម្យ៉ាង ដែលជាធម្មតាមិនឃើញមាននៅក្នុងចំណោមទាហានទេ ។ សព្វថ្ងៃនេះ ប៉ៃលិននៅបន្តជួបប្រទះនូវបញ្ហាក្នុងការអភិវឌ្ឍ ប៉ុន្តែបើទោះបីជាយ៉ាងនេះក៏ដោយ ប្រវត្តិរបស់តំបន់នេះបានបង្ហាញនូវការផ្សះផ្សាមួយយ៉ាងរស់រវើកជាមួយអតីតកាល ជាមួយបរិស្ថានដែលបង្កបង្កើតឡើង និងជាមួយប្រជាជាតិ ។